តុលាការកំពូល និងមហាអយ្យការ
អមតុលាការកំពូល
លេខ ០៣.តកក.នសកត

# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

# ប្រធានតុលាការកំពូល

**ជម្រាបមក**

## លោកជំទាវប្រធានសាលាឧទ្ធរណ៍
## លោកប្រធានតុលាការគ្រប់ខេត្ត-ក្រុង

**កម្មវត្ថុ:** អំពីការប្រើប្រាស់សិទ្ធិឆ្លើយតប ឬ កែតម្រូវចំពោះអត្ថបទសារព័ត៌មានទាំងឡាយ ដែលចុះផ្សាយខុសពីការពិត ទាក់ទងនឹងរឿងក្តីរបស់តុលាការ ។

**យោង:** -មាត្រា ៧-១០ និង ១៣ នៃច្បាប់ស្តីពីរបបសារព័ត៌មាន

-មាត្រា ៦២ និង ៦៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល

កន្លងមកតុលាការកំពូលបានកត់សម្គាល់ឃើញថា លោកជំទាវ ឯកឧត្តម លោក លោកស្រីជាចៅក្រម និងព្រះរាជអាជ្ញា បានខិតខំប្រឹងប្រែងយ៉ាងច្រើនឥតគណនា ដើម្បីដោះស្រាយរឿងក្តី ស្វែងរកយុត្តិធម៌ជូនពលរដ្ឋស្លូតត្រង់ និងការពារសណ្តាប់ធ្នាប់ សន្តិសុខ សុវត្ថិភាពសង្គម ក្នុងព្រះរាជាណាចក្រកម្ពុជាទាំងមូលធ្វើអោយសង្គមជាតិយើងមានការរីកចម្រើន ជាបន្តបន្ទាប់តាមបែបនីតិរដ្ឋ ។

ប៉ុន្តែជាការគួរអោយសោកស្តាយណាស់ ដែលការខិតខំប្រឹងប្រែងទាំងអម្បាលមាន ព្រមទាំងលទ្ធផលដ៏ល្អប្រសើររបស់យើង ពុំត្រូវបានបណ្តាញសារព័ត៌មានយកមកចុះផ្សាយទេ ផ្ទុយទៅវិញស្ទើរតែរាល់ថ្ងៃយើងតែងសង្កេតឃើញនៅលើទំព័រសារព័ត៌មាន សុទ្ធតែជាព័ត៌មានអាក្រក់ៗពីចៅក្រម និងព្រះរាជអាជ្ញាយើង ។ តុលាការកំពូលតែងបានយកចិត្តទុកដាក់ស្រាវជ្រាវលើគ្រប់ករណីដែលបានចុះផ្សាយលើសារព័ត៌មានទាំងនោះ ។ លទ្ធផលបង្ហាញអោយឃើញថា មានតែព័ត៌មានតិចតួចបំផុតដែលបានចុះផ្សាយតាមការពិត រីឯព័ត៌មានភាគច្រើន គឺផ្សាយខុសពីការពិតដោយស្តាប់សម្តីតែភាគីម្ខាង ។ ប្រការទាំងនេះបានធ្វើអោយមជ្ឈដ្ឋានប្រជាពលរដ្ឋ និងមតិអន្តរជាតិ យល់ច្រលំទាំងស្រុង និង អស់ជំនឿលើស្ថាប័នតុលាការនៅកម្ពុជា ហើយសាមីខ្លួនដែលរងគ្រោះដោយអត្ថបទសារព័ត៌មាននោះពុំដែលសុំកែតម្រូវ ឬ ឆ្លើយតបទេ ដោយលើកមតិថា មិនចង់មានទំនាស់ជាមួយអ្នកកាសែត ឬថាកុំរវល់ជាមួយអ្នកកាសែតដែលទស្សនៈបែបនេះគឺជាការខុសឆ្គងបណ្តោយអោយគេជាន់ឈ្លីកិត្តិយសរបស់តុលាការដោយអយុត្តិធម៌។

អាស្រ័យហេតុនេះ ចាប់ពីពេលនេះតទៅ សូមលោកជំទាវ ឯកឧត្តម លោក លោកស្រី ដែលជាចៅក្រម ព្រះរាជអាជ្ញា ប្រើប្រាស់សិទ្ធិរបស់ខ្លួនធ្វើការឆ្លើយតប ឬ កែតម្រូវនូវព័ត៌មានមិនពិតទាំងនោះតាមមាត្រា ១០ នៃច្បាប់ស្តីពីរបបសារព័ត៌មាន ។ ប៉ុន្តែអត្ថបទឆ្លើយតប ឬ កែតម្រូវ គប្បីសរសេរអោយបានខ្លី និយាយអោយចំបញ្ហាអោយងាយយល់ និងមានខ្លឹមសារគ្រប់គ្រាន់ ដោយជៀសវាងនូវពាក្យ ឬ ខ្លឹមសារណាដែលមានន័យផ្ចាញ់ផ្ចាល ឬហិង្សា ឬ បង្កជំលោះ ឬ សំដែងអោយឃើញនូវភាពមិនថ្លៃថ្នូររបស់ខ្លួនជាចៅក្រម ។

ក្នុងករណីដែលសារព័ត៌មាននោះពុំព្រមចុះផ្សាយនូវអត្ថបទកែតម្រូវ ឬ ឆ្លើយតបទេ នៅតែបន្តផ្សាយបំភ្លើសថែមទៀត ចៅក្រម ឬ ព្រះរាជអាជ្ញាដែលរងគ្រោះមានសិទ្ធិប្តឹងទៅព្រះរាជអាជ្ញាសារព័ត៌មាន និងច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

ខ្ញុំសង្ឃឹមថា លោកជំទាវ ឯកឧត្តម លោក និង លោកស្រី ដែលជាចៅក្រម និងព្រះរាជអាជ្ញា ទាំងអស់យកចិត្តទុកដាក់កែតម្រូវ ឬ ឆ្លើយតបអោយទាន់ពេលវេលា ដើម្បីអោយមតិសាធារណៈយល់ច្បាស់អំពីករណីនីមួយៗដែលត្រូវបានចោទឡើងនៅក្នុងសារព័ត៌មានទាំងនោះ ។

ភ្នំពេញ ថ្ងៃទី២៥ ខែមករា ឆ្នាំ២០០៥

**ឌិត មុន្ទី**

<u>ចម្លងជូន</u>

-ក្រសួងយុត្តិធម៌
-ក្រសួងព័ត៌មាន
-លេខាធិការដ្ឋាន ឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រម
-មហាអយ្យការអមតុលាការកំពូល
-មហាអយ្យការអមសាលាឧទ្ធរណ៍
-អយ្យការអមតុលាការគ្រប់ខេត្ត-ក្រុង
-ឯកសារ